# ភាពស្ថិតស្ថេរនៃអនាគត ៖

# ការទាក់ទាញចំណាប់អារម្មណ៍យុវជន
# ឱ្យវិលត្រឡប់ទៅរកវិស័យកសិកម្មវិញ



*ទស្សវដ្ដីអាហ្វា*

**សួរ. វិភាគ. តស៊ូមតិ. ធ្វើសកម្មភាព!**


សមាគមកសិករអាស៊ី
ដើម្បីការអភិវឌ្ឍន៍
ប្រកបដោយនិរន្តរភាព

វ៉ុលុម៧
លេខ១
ខែមិថុនា ២០១៥

ភាពជាយុវវ័យ (យុវជន) គឺសំដៅដល់ពេលវេលាមួយ ដែលមនុស្សម្នាក់ៗបានចាប់ផ្ដើមបង្កើតក្ដីសុបិន្តអំពីអនាគតទៅតាមគន្លងវិថីមួយ ដែលត្រូវដើរដោយចិត្តអង់អាចក្លាហាន និងមានផែនការជីវិតរបស់ខ្លួនជាក់លាក់។ នៅតាមជនបទ ការធ្វើ ឬក្លាយខ្លួនជាកសិករម្នាក់វាមិនមែនជាផ្នែកមួយនៃក្ដីសុបិនអំពីពេលអនាគត ដែលបានចែងខាងលើនេះទេ។ ការធ្វើកសិកម្មគឺ ជាការធ្វើការងារតូចទាប និងរកប្រាក់កម្រៃតិចតួច ជាហេតុនាំអោយពួកគេយល់ថា ការធ្វើចំណាកស្រុកទៅកាន់ទីក្រុង ឬនៅបរទេស ដែលជាកន្លែងមានឱកាសកាន់តែច្រើន និងការផ្សងព្រេងកាន់តែល្អប្រសើរជាង។

**តើអនាគតវិស័យកសិកម្ម និងស្បៀងអាហាររបស់យើង នឹងទៅជាយ៉ាងណា បើសិនជាអត់មានកសិករវ័យក្មេង (យុវកសិករ)? គ្មានកសិករ គឺគ្មានអាហារ...គ្មានអាហារ គឺគ្មានជីវិត។**

នៅក្នុងទស្សនាវដ្ដីនេះ (ទស្សនាវដ្ដីអាហ្វា) យើងនឹងពិភាក្សាអំពីមូលហេតុមួយចំនួន ថាហេតុអ្វីបានជាកសិករវ័យក្មេង (យុវកសិករ) មិនសូវមានការចាប់អារម្មណ៍ក្នុងវិស័យកសិកម្ម? តើមានគំនិតផ្ដួចផ្ដើមអ្វីខ្លះ ដើម្បីជម្រុញលើកទឹកចិត្តដល់យុវជនឱ្យវិលត្រឡប់ទៅក្នុងវិស័យកសិកម្ម? តើមានអនុសាសន៍អ្វីខ្លះដើម្បីជួយឱ្យយុវជនបន្តស្នាក់នៅជនបទធ្វើកសិកម្ម។ អ្វីដែលត្រូវពិភាក្សាពេលនេះ គឺជាលទ្ធផលសំយោគរវាង (ក) លទ្ធផលពិគ្រោះយោបល់ និងស្រាវជ្រាវថ្នាក់ជាតិ ដែលរៀបចំឡើងដោយសមាជិករបស់អាហ្វា ចំនួន៩ប្រទេស ដែលពាក់ព័ន្ធជាមួយយុវជនជនបទប្រមាណជា ៦៦០នាក់ ស្ដីពី «ការទាក់ទាញយុវជនឱ្យងាកទៅរកវិស័យកសិកម្ម» ដោយប្រើវិធីសាស្ត្រឧបករណ៍ ពិគ្រោះយោបល់តស៊ូមតិរបស់កសិករ (ហ្វៃក) ដែលគាំទ្រដោយអាគ្រីទែរ៉ា (Agriterra) (ខ) លទ្ធផលនៃការពិគ្រោះយោបល់ថ្នាក់តំបន់បានពាក់ព័ន្ធជាមួយបុរសចំនួន៣០នាក់ និងស្ត្រីចំនួន១០នាក់ ជាតំណាងអង្គការកសិករថ្នាក់ជាតិចំនួន១៧ នៅក្នុងប្រទេសចំនួន១៣ ដែលបានប្រារព្ធឡើងកាលពីខែឧសភា ឆ្នាំ២០១៤ និងពិនិត្យឡើងវិញ (គ) ទិន្នន័យ ស្រាវជ្រាវតាមឯកសារពីបណ្ណាល័យ។ អាហ្វាបានរៀបចំការពិគ្រោះយោបល់ទាំងនេះក្នុង ការប្រារព្ធទិវាឆ្នាំនៃគ្រួសារកសិករអន្តរជាតិ (*IYFF* អាយ.វ៉ាយ.អេហ្វ.អេហ្វ) ខណៈដែលបញ្ហាយុវជនក្នុងវិស័យកសិកម្ម គឺជាបញ្ហាមួយក្នុងចំណោមបញ្ហាអាទិភាពរបស់ អាយ.វ៉ាយ.អេហ្វ.អេហ្វ។



## តើយុវជនជាអ្នកណា?

បច្ចុប្បន្នចំនួនយុវជន (តាមនិយមន័យរបស់អង្គការសហប្រជាជាតិគឺចន្លោះពីអាយុ១៥ឆ្នាំ ទៅ២៤ឆ្នាំ) មានចំនួនច្រើនបំផុតនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ ក្នុងរបាយការណ៍ឆ្នាំ២០១២ បង្ហាញថាចំនួនយុវជនកើនឡើងដល់១.៨ពាន់លាននាក់ ឬស្មើនឹង១៨% នៃចំនួនប្រជាជនសរុបរបស់ពិភពលោក។ ចំនួនប្រមាណជា ៩០% ក្នុងចំណោមយុវជនវ័យក្មេងទាំងនេះកំពុងរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ឬប្រមាណ២០% នៃចំនួនប្រជាជនសរុបរបស់ប្រទេសនិមួយៗ។

ទិន្នន័យរបស់អង្គការសហប្រជាជាតិអេសស្កាប់ (UNESCAP) ឆ្នាំ២០១២ បានបង្ហាញថាយុវជនចំនួន៧៥០លាននាក់ ឬ ប្រមាណជាង៦០% នៃយុវជនរបស់ពិភពលោកគឺកំពុង រស់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ របាយការណ៍ឆ្នាំ២០១០ បានបង្ហាញថា ប្រទេសឥណ្ឌា មានចំនួនយុវជនច្រើនបំផុត (២៣៤លាននាក់) នៃចំនួនយុវជនវ័យក្មេងក្នុងពិភពលោក ឬ ១៩% នៃចំនួនប្រជាជនសរុបរបស់ប្រទេសឥណ្ឌា។ បន្ទាប់មកប្រទេសចិនបានជាប់ចំណាត់ថ្នាក់លេខ២ ក្នុងបញ្ជីប្រទេស ដែលមានចំនួនយុវជនច្រើនជាងគេបំផុតនៅលើពិភពលោកគឺប្រមាណ២២៥លាននាក់ ឬស្មើ១៧% នៃចំនួនប្រជាជនសរុបចិន។ ប្រទេសបង់ក្លាដែស និងហ្វីលីពីន មានប្រជាជនវ័យក្មេងប្រមាណ ២០% នៃចំនួនប្រជាជនសរុបរបស់ប្រទេស។ ប្រទេសជប៉ុនមានយុវជនវ័យក្មេងចំនួន ១២លាននាក់ ឬ ១០% នៃចំនួនប្រជាជនសរុបរបស់ប្រទេស។ មានប្រទេសជាច្រើនបានឱ្យនិយមន័យផ្សេងៗគ្នាតាមប្រទេសរបស់ខ្លួន អំពីអាយុរៀងៗខ្លួនអាស្រ័យលើកត្តាសង្គម វប្បធម៌ និងសេដ្ឋកិច្ចជាក់លាក់។ យុវជនត្រូវបានកំណត់នៅក្នុងច្បាប់របស់ប្រទេសនិមួយសម្រាប់បុរស និងស្ត្រីវ័យក្មេង ដែលមានអាយុចន្លោះពី១២-២៤ឆ្នាំ (នៅតៃវ៉ាន់) ពី១៤-២៨ឆ្នាំ (នៅកៀហ្ស៊ីស៊ីស្ថាន)ពី១៥-២៥ (ប្រទេសថៃ) ពី១៥/១៦-៣០ (នៅប្រទេសហ្វីលីពីន កម្ពុជា ឥណ្ឌូនេស៊ី និងវៀតណាម) ពី១៥-៣៤ឆ្នាំ (ម៉ុងហ្គោលី) ពី១៥-៤០ឆ្នាំ (ប្រទេសនេប៉ាល់) ពី១៨-៣៥ឆ្នាំ (មីយ៉ាន់ម៉ា) ពី៩-២៤ឆ្នាំ (នៅកូរ៉េខាងត្បូង) និងពី០-៣០ឆ្នាំ (នៅប្រទេសជប៉ុន)។

## យុវជននៅតំបន់ជនបទ

មានយុវជនរហូតដល់៧០ភាគរយ នៃចំនួនយុវជនក្នុងពិភពលោកកំពុងរស់នៅក្នុងតំបន់អនុតំបន់សាហារ៉ានៃទ្វីបអាហ្វ្រិក និងអនុតំបន់ជនបទនៃទ្វីបអាស៊ី ហើយចំនួនជាងពាក់កណ្ដាលនៃពួកគេកំពុងវិនិយោគ ឬលក់កម្លាំងពលកម្មក្នុងវិស័យកសិកម្ម[1]។




[1]. http://www.ilo.org/wcmsp5/groups/public/---ed_emp/documents/publication/wcms_182750.pdf

ជាច្រើន ទសវត្សរ៍មកហើយ យុវជននៅតាមជនបទ មិនសូវទទួលបានការយកចិត្តទុកដាក់ពីសហគមន៍ ឬរដ្ឋាភិបាលរបស់ពួកគេ ព្រមទាំងអង្គការអន្តរជាតិផងឡើយ។ ហេតុនេះបានធ្វើឱ្យការប្រើប្រាស់ថាមពល និងសក្តានុពលរបស់ពួកគេនៅក្នុងវិស័យកសិកម្មមិនបានពេញលេញឡើយ។ ជាទូទៅ យុវជននៅតាមជនបទគ្មានការងារធ្វើឡើយ ឬធ្វើការងារក្រៅផ្លូវការដោយគ្មានប្រាក់កម្រៃ ឬប្រាក់កម្រៃទាប ដោយខ្វះជំនាញ ជាមួយនឹងប្រភេទការងារប្រកបអសន្តិសុខ និងគ្រោះថ្នាក់។ កង្វះឱកាស និងការងារសមរម្យនៅក្នុងតំបន់ជនបទ បានច្រានបង្ខំយុវជន ឱ្យធ្វើចំណាកស្រុកទៅរកការងារនៅតំបន់ទីក្រុង។ មិនថាកូនប្រុស ឬកូនស្រីទេ របស់គ្រួសារកសិករ ជាទូទៅតែងមានការស្ទាក់ស្ទើរ ឬមិនពេញចិត្ត ក្នុងការធ្វើកសិកម្មទេ ដោយមានហេតុផលច្រើនយ៉ាង។ យុវជនជាច្រើន ដែលបន្តស្នាក់នៅក្នុងកសិដ្ឋានធ្វើកសិកម្ម ជាទូទៅគឺដោយសារការបង្ខំ ចិត្ត ឬ គ្មានជម្រើសអ្វីផ្សេងប្រសើរជាងនេះ។ បញ្ហានេះ បានបណ្តាលឱ្យមានបញ្ហាមួយផ្សេងទៀត នោះគឺការបន្សល់ទុកនូវចំនួនប្រជាជន ឬកសិករដែលមានវ័យចំណាស់កាន់តែច្រើនឱ្យបន្តធ្វើការងារកសិកម្ម។ ប្រសិនបើយុវជនត្រូវបានគេគិតថាគឺជាអនាគតនៃប្រទេសជាតិនិមួយៗ ហើយយុវជនជនបទ គឺជាស្នូលនៃអនាគតវិស័យកសិកម្ម និងឧស្សាហកម្មនៅជនបទ អញ្ចឹងតើយើងត្រូវមានយុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីទាក់ទាញចំណាប់អារម្មណ៍យុវជនឱ្យបន្តស្នាក់នៅ ឬធ្វើការងារកសិកម្មនៅតាមតំបន់ជនបទ? តើមានគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍អ្វីខ្លះ ដែលត្រូវការចាំបាច់បំផុត ដើម្បីជួយឱ្យយុវជនមើលឃើញថាអនាគតល្អ កំពុងរង់ចាំពួកគេនៅឯជនបទ បន្ទាប់មកពួកគេបានសម្រេចចិត្តរស់នៅបន្ត ដោយចាប់យកវិស័យកសិកម្ម និងកសិឧស្សាហកម្មនៅជនបទ?

**ហេតុអ្វីបានជាមុខរបរកសិកម្មគ្មានការទាក់ទាញ ឬចំណាប់អារម្មណ៍ សម្រាប់យុវជន**

តាមរយៈលទ្ធផលពិគ្រោះយោបល់ថ្នាក់ជាតិ និងថ្នាក់តំបន់របស់មេដឹកនាំយុវកសិករដែលជាសមាជិករបស់សមាគមកសិករអាស៊ី (អាហ្វា) ជាមួយនឹងទិន្នន័យបន្ថែម ដែលបានមកពីការស្រាវជ្រាវក្នុងបណ្ណាល័យផងនោះ យើងបានរកឃើញថា មានហេតុផលចំនួនប្រាំពីរ (៧) យ៉ាង ដែលបានបង្ហាញថាមុខរបរកសិកម្មគ្មានការទាក់ទាញ ឬគ្មានចំណាប់អារម្មណ៍ពីយុវជន ហើយសូម្បីតែកូនប្រុសកូនស្រីនៃគ្រួសារកសិករសុទ្ធសាធក៏មិនធ្វើកសិកម្មដែរ ប្រសិនបើឱ្យឱកាសពួកគេធ្វើការជ្រើសរើសនោះ។ **ហេតុផលទាំង៧គឺ៖**

***១. រូបភាព និងអត្តសញ្ញាណជាកសិករមានតម្លៃអម្រិតទាប៖*** មុខរបរសិកម្មត្រូវបានគេចាត់ទុកថាជាការងារទន់ទាប រកបានតែមួយគៃរៗ ជាការងារកខ្វក់ ពិសេសជាការងារប្រើកម្លាំងបាយដោយមិនចាំបាច់មានចំណេះជំនាញអ្វីខ្ពង់ខ្ពស់ឡើយ។ ជាទូទៅ ការធ្វើស្រែចំការ (និយាយឱ្យចំទៅគឺមុខរបរស្រែចំការ ឬហៅថាអ្នកស្រែ) មិនសូវធ្វើឱ្យយុវជនមានមោទនភាព និងសេចក្តីថ្លៃថ្នូរប៉ុន្មាននទេក្នុងសង្គមនោះ។ ផ្នត់គំនិតបែបនេះ ចេះតែបន្តកើនឡើងៗនៅក្នុងសង្គម។ ឪពុកម្តាយជាកសិករតែងប្រដៅកូនចៅរបស់ពួកគេថា «បើកូនមិនខិតខំប្រឹងសិក្សារៀនសូត្រឱ្យពូកែទេ ចុងក្រោយអនាគតកូនៗនឹងបញ្ចប់នៅទីនេះ គឺធ្វើស្រែចំការស្នងពីពុកម៉ែទៀតហើយ»។ ***កូនអើយ*** «កុំឱ្យមានវាសនាដូចជាពុកម៉ែទៀតណា ធ្វើស្រែចំការហត់នឿយណាស់ មានឋានៈតូចទាប រកស៊ីបានតែមួយគៃរៗ ចិញ្ចឹមតែក្រពះមិនចង់រស់ផង»។ «បើកូនរៀន

មិនពូកែ កូនត្រូវត្រឡប់ទៅចំតិតកណ្ដាលវាលស្រែស្ទូងស្រូវដូចពុកម៉ែទៀតហើយ»។ សិស្សសាលាភាគច្រើនសុបិនចង់ក្លាយជាវេជ្ជបណ្ឌិត វិស្វករ ឬមេធាវី ហើយជាការកម្រណាស់ ដែលសុបិនចង់ក្លាយជាកសិករនោះ។ កសិករតែងតែត្រូវបានគេចាត់ទុកជាមនុស្សនៅស្រទាប់ក្រោមគេ នៅក្នុងប្រទេសកំពុងអភិវឌ្ឍហើយត្រូវបានកំណត់ថាជាអ្នកគ្មានចំណេះដឹង ឬមិនស៊ីវិល័យ (Shrestha ឆ្នាំ 2001: 114-115)។

***២. មុខរបរធ្វើកសិកម្មមិនមែនជាមុខរបរដែលរកផលកម្រៃ/ចំណេញច្រើននោះ:*** *ចំពោះកសិករ ឬភាសាសាមញ្ញហៅថា (អ្នកស្រែ) ភាគច្រើនបំផុតគឺមានជីវភាពក្រីក្រ។ ពួកគេមិនទទួលបានផលកម្រៃប្រាក់ចំណូលគ្រប់គ្រាន់ពីវិស័យកសិកម្មឡើយ គឺវាស្ថិតនៅឆ្ងាយខ្លាំងណាស់ពីតម្រូវការក្រុមគ្រួសាររបស់ពួកគេ ឬពេលខ្លះសឹងតែចិញ្ចឹមខ្លួនឯងមិនចង់រស់ផង។ ចំណុចសំខាន់ គឺថាពេលប្រាក់ចំណូលពីវិស័យកសិកម្មថយចុះដោយសារតម្លៃផលិតផលទាប បែរជាកំណើននៃការចំណាយឡើងខ្ពស់ទៅវិញដោយសារតម្លៃគ្រាប់ពូជ ជី ថ្នាំសម្លាប់សត្វល្អិត និងសម្ភារៈកសិកម្មមួយចំនួនទៀតមានតម្លៃខ្ពស់។ ជាមួយគ្នានោះដែរកង្វះលទ្ធភាពក្នុងការវាយលុកចូលទីផ្សាររបស់កសិករ ហានិភ័យខ្ពស់ក្នុងវិស័យកសិកម្មដោយសារកត្តានិងលក្ខខណ្ឌអាកាសធាតុដែលមិនអាចទាយទុកជាមុនបាន និងភាពគ្មានលំនឹងនៃការឡើងចុះតម្លៃទីផ្សារ។ល។ ទាំងអស់នោះហើយជាមូលហេតុចំបង ដែលមិនអាចរក្សា ឬទាក់ទាញចំណាប់អារម្មណ៍របស់យុវជនមិនឱ្យរត់ចោលមុខរបរកសិកម្មនោះ។ ការធ្វើកសិកម្មដើម្បីគ្រាន់តែចិញ្ចឹមជីវិតឱ្យតែរស់ៗនោះគឺជាឧបសគ្គ និងជាកត្តាបង្អាក់ រាំងយុវជនក្នុងការចូលប្រឡូក ឬចាប់យកវិស័យកសិកម្មនោះ។ ពួកគេមើលឃើញថា ការប្រកបរបរកសិកម្មបានផ្ដល់ផលប្រយោជន៍តែម្យ៉ាងគត់ដល់គ្រួសារកសិករ គឺបានត្រឹមតែសម្រាប់ហូបចុកក្នុងគ្រួសារប៉ុណ្ណោះ ជាហតុធ្វើឱ្យយុវជនគ្មានភាពកក់ក្ដៅ គ្មានក្ដីរំពឹង និងមើលមិនឃើញពីភាពភ្លឺស្វាងណាមួយក្នុងជីវិតរបស់ពួកគេ នាពេលអនាគតពីការប្រកបរបរកសិកម្មឡើយ។*



**៣. អសន្តិសុខកម្មសិទ្ធិដីធ្លី និងបញ្ហាតម្លៃដីឡើងថ្លៃ:** ចាប់តាំងពីឆ្នាំ១៩៩០មក បរិបទនៃចលនាកំណែទម្រង់ដីធ្លីលក្ខណៈសកល មាននិន្នាការផ្លាស់ប្តូរពីការធ្វើកសិកម្មខ្នាតតូចទៅជាការធ្វើកសិកម្មខ្នាតធំវិញ និងចលនាកំណែទម្រង់ដីធ្លីដែលមានលក្ខណៈទីផ្សារដឹកមុខ (Borras, 2006: 99) បានរីកពលដាលខ្លាំង ដូចជា៖ តំបន់សេដ្ឋកិច្ចពិសេសតាមរយៈ ការធ្វើឯកជនភាវូបនីយកម្ម ដោយបំលែងដីទីក្រុង/ជាយក្រុងឱ្យទៅជាទំនិញ ដែលអាចទិញដូរបាននៅក្នុងទីផ្សារសេរី (Kumar ជា 2011)។ ដោយសារតែតម្លៃដីធ្លី មានលក្ខណៈជាទីផ្សារដឹកមុខ និងកំណែទម្រង់ដីធ្លីកសិកម្ម បណ្តាលឱ្យតម្លៃដីបានកើនឡើងខ្ពស់។ វប្បធម៌ប្រពៃណីរបស់អ្នកស្រែចំការ និងកសិករផ្ទាល់ គឺមិនមានឯករាជ្យ ឬភាពម្ចាស់ការលើខ្លួនឯងបានពីគ្រប់ខណ្ឌនៃវណ្ណៈសង្គមឡើយ។ ធនាគារ/មូលធនដីធ្លី បានជំរុញទីផ្សារដីធ្លី និងការបណ្តេញកសិករចេញពីដីរបស់ពួកគេ។ វាបានក្លាយទៅជាឧបករណ៍ដើម្បីគ្រប់គ្រងដីធ្លី និងធ្វើឱ្យដីក្លាយជាទំនិញមួយប្រភេទ ដែលអាចទិញលក់ និងរកប្រាក់ចំណេញបានច្រើន (Hu Ban Yeh និងលោក Wu, 2009)។ ប្រការនេះបានធ្វើឱ្យកសិករ ដែលជាអ្នកត្រូវធ្វើកសិកម្មដាំដុះលើដីនោះ ត្រូវបានគេដកហូតកម្មសិទ្ធិ ចំណែកអ្នកដែលក្លាយជាម្ចាស់កម្មសិទ្ធិគឺជាឈ្មួញ ដែលមិនបានដាំដុះអ្វី ហើយទុកដីទំនេរចោលទៅវិញ។ ការរឹបអូសដីពីកសិករហើយប្រគល់ទៅឱ្យក្រុមហ៊ុនឯកជន ជាពិសេសពួកផ្សំគំនិតកេងប្រវ័ញ្ចដីធ្លី ឬឧស្សាហករធំៗដូច្នេះហើយគឺជាកត្តា ធំបំផុតបណ្តាលយុវជនចំណាកស្រុកបោះបង់មុខរបរកសិកម្ម (Kumar ២០១១)។ កំណែទម្រង់ដីធ្លីនាពេលបច្ចុប្បន្ននេះ បានគេផ្តោតទៅលើការធ្វើទំនើបកាវូបនីយកម្ម វិស័យកសិកម្ម ជាជាងការបែងចែក និងសន្តិសុខដីធ្លី និងសិទ្ធិកាន់កាប់របស់កសិករ រួមទាំងកសិករវ័យក្មេងផងដែរ។

**៤. ការខ្វះខាត ហេដ្ឋារចនាសម្ព័ន្ធជនបទ:** មូលដ្ឋាននៃវិស័យកសិកម្មនៅតែស្ថិតនៅឯតំបន់ជនបទ។ យ៉ាងណាក៏ដោយ យើងកំពុងប្រឈមបញ្ហាកង្វះខាតហេដ្ឋារចនាសម្ព័ន្ធ និងស្ថាប័នដ៏ល្អៗក្នុងការទាក់ទាញចំណាប់យុវជនឱ្យស្នាក់នៅក្នុងតំបន់ជនបទ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ តំបន់ជនបទភាគច្រើនគ្មានផ្លូវថ្នល់ល្អ គ្មានអគ្គិសនី គ្មានគ្លីនិក គ្មានមណ្ឌលសុខភាព គ្មានមន្ទីរពេទ្យ គ្មានសាលារៀននិងសាកលវិទ្យាល័យ គ្មានឧទ្យាននិងសួនកំសាន្ត គ្មានបណ្តាញអ៊ីនធឺណិត គ្មានការបង្កើតអាជីវកម្ម គ្មានទីផ្សារសម្រាប់លក់ផលិតផលរបស់កសិករ ខ្វះខាតកន្លែង និងសម្ភារៈកសិកម្មសម្រាប់ខ្នាតតូច និងខ្នាតមធ្យម ក្នុងវិស័យកសិឧស្សាហកម្ម ឬ ពេងចក្រ។

**៥. ខ្វះគោលនយោបាយ និងកម្មវិធីរបស់រដ្ឋាភិបាលដើម្បីគាំទ្រជួយក្រុមគ្រួសារកសិករ:** រដ្ឋាភិបាលជាច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បានផ្តល់អាទិភាពដល់ការធ្វើកសិកម្មខ្នាតធំរបស់ក្រុមហ៊ុន ជាជាងការធ្វើកសិកម្មលក្ខណៈគ្រួសាររបស់កសិករ។ ដូច្នេះគោលនយោបាយកសិកម្ម និងកម្មវិធីអភិវឌ្ឍន៍នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ស្ទើរតែមិនបានគាំទ្រដល់គ្រួសារកសិករឡើយ ថ្វីបើការពិតថាពួកគេ (កសិករ) គឺជាចំនួនភាគច្រើននៃប្រជាជននៅក្នុងប្រទេសនិមួយៗ និងនៅក្នុងតំបន់អាស៊ីទាំងមូលក៏ដោយ។ ដូច្នេះកសិករភាគច្រើននៅតែខ្វះខាតដីធ្លីធ្វើកសិកម្ម ខ្វះឥណទាន/ការផ្តល់ហិរញ្ញវត្ថុ និងកង្វះលទ្ធភាពចូលទីផ្សារ។ ប្រព័ន្ធឥណទាន និងធនាគារពាណិជ្ជផ្តូវការគាំទ្រដល់ ការធ្វើកសិកម្មជាលក្ខណៈពាណិជ្ជកម្ម បានបំផ្លាញដល់សេដ្ឋកិច្ចគ្រួសាររបស់កសិករ ដែលធ្វើកសិកម្មជាលក្ខណៈគ្រួសារ និងបង្កើត

សេដ្ឋកិច្ចទីផ្សារជំនួសវិញ (Harvey ២០០៣: ១៥៦-១៦៦)។ តម្លៃផលិតផលកសិកម្ម ត្រូវបានគ្រប់គ្រងដោយទីផ្សារនេះ (ឈ្មួញ) មិនមែនក្នុងដៃកសិករ ឬរដ្ឋឡើយ។ បញ្ហាគឺកង្វះខាតនូវតម្លាភាពក្នុងការកំណត់តម្លៃ ការកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងការបង្កើតគោលនយោបាយគាំទ្រដល់កសិករ (លោក Ahmad et al ២០១០ ទំព័រ៣៧)។ កសិករមិនត្រូវបានគេផ្តល់ឱកាសឱ្យមានអ្នកតំណាងឡើយ ដូច្នេះហើយបានជាគ្មាន ឬមានសំឡេងតិចតួច នៅក្នុងដំណើរការ និងក្រុមអ្នកមានសិទ្ធិធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗលើបញ្ហាកសិកម្មនោះ។ មិនត្រឹមតែប៉ុណ្ណោះ ការខ្វះខាតគោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីដោះស្រាយបញ្ហាតម្រូវការរបស់យុវជនតាមជនបទ ឬកសិករវ័យក្មេង ការផ្តួចផ្តើម និងការលើកទឹកចិត្តនានាតិចតួចបំផុត ឬស្ទើរអវត្តមានទាំងស្រុងសម្រាប់ពួកគេ។ បើគ្មានការគាំទ្រឬផ្តល់តម្រូវការចាំបាច់ទាំងនេះដល់កសិករវ័យក្មេងទេ ពួកគេនឹងមានអារម្មណ៍ថា ពួកគេមិនអាចប្រកួតប្រជែងជាមួយកសិករពាណិជ្ជកម្មធំៗបានឡើយ។

***៦. កង្វះខាតកម្មវិធីសិក្សាអំពីដីធ្លី កំណែទម្រង់ដីធ្លី និងកសិកម្ម:*** កសិកម្ម គឺជាប្រភពដ៏សំខាន់ក្នុងការផ្តល់ការងារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ កម្មវិធីសិក្សាក្នុងសាលា និងសាកលវិទ្យាល័យរបស់ប្រទេសទាំងនេះ ទោះយ៉ាងណា មិនបានដាក់បញ្ចូលបញ្ហាដី និងកសិកម្ម ជាលទ្ធផលនៅក្នុងការធ្វេសប្រហែសនៃការធ្វើកំណែទម្រង់កសិកម្ម គឺជាកត្តា បាក់ទឹកចិត្តកសិករវ័យក្មេងឱ្យចាកចោលវិស័យកសិកម្ម។

***៧. កង្វះអង្គការយុវកសិករ:*** ទាំងនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ ការរៀបចំយុវជនឱ្យមានជាក្រុម ជាអង្គការចាត់តាំងច្បាស់លាស់ មានចំនួនតិចតួចបំផុត សម្រាប់បង្កើនចំណងសាមគ្គីភាព ការផ្លាស់ប្តូរព័ត៌មានសម្រាប់គាំទ្រដល់ការខិតខំប្រឹងប្រែង និងសម្រាប់តំណាងឱ្យផលប្រយោជន៍របស់យុវជនក្នុងជួរគណៈកម្មការ ដែលមានសិទ្ធិធ្វើសេចក្តីសម្រេច។

---



**បញ្ហាប្រឈមរបស់យុវជន និងយុវកសិករវ័យក្មេង**

យុវជន ដែលចូលរួមប្រឡូកនៅក្នុងវិស័យធ្វើកសិកម្មបានប្រឈមមុខនឹងការបញ្ហាជាច្រើនក្នុងនោះរួមមាន:

ក. ***យុវជនខ្វះលទ្ធភាពទទួលបាននិងការត្រួតត្រាពិនិត្យលើធនធានផលិតភាព (ដូចជាដី មូលធន) និងទីផ្សារ៖***

<u>ទី១</u>៖ គឺថាគ្មានកំណែទម្រង់ដីធ្លី និងកសិកម្មណាមួយផ្តោតការយកចិត្តទុកដាក់សំខាន់លើកសិករវ័យក្មេងឡើយនៅក្នុងប្រទេសអាស៊ីភាគច្រើន។ ជាលទ្ធផលគឺថាភាគច្រើននៃកសិករវ័យក្មេងទាំងនោះ គ្មានលទ្ធភាពទទួលបានដីសម្រាប់ធ្វើកសិ-ពាណិជ្ជកម្ម (Wobst 2010) ឡើយ។

*ពួកគេគឺជាជនដែលគ្មានដីធ្លី ហើយជាញឹកញាប់បានក្លាយជាកម្លាំងពលកម្មសម្រាប់វិស័យកសិកម្មតាមរដូវកាល។ **ទីពីរ៖** កសិករវ័យក្មេងជាច្រើន ដែលត្រូវរង់ចាំរហូតដល់ពួកគេបានទទួលដីជាកេរ្តិ៍មត៌កពីឪពុក ម្តាយរបស់ពួកគេ។ ខណៈពេលដែលពួកគេធ្វើការងារ ក្រោមស្វាមីឪពុកម្តាយរបស់ពួកគេនោះពួក គេមានការសម្រេចចិត្តតិចតួចបំផុតលើការធ្វើកសិកម្ម។ **ទីបី៖** ស្ទើរតែគ្មានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុណាមួយបម្រើឱ្យវិស័យកសិកម្មនោះទេ ឬ ប្រសិនបើមាន ក៏ការយល់ដឹងរបស់ពួកគេ ចំពោះតម្រូវការរបស់យុវសហគ្រិន (សហគ្រិនវ័យក្មេង) នៅទន់ខ្សោយ ដែរ។ **ទីបួន៖** កសិករវ័យក្មេងជាច្រើនមិនទាន់បានបង្កើតទីផ្សារ (ចក្ខុវិស័យ និងក្តីសុបិន) របស់ពួកគេនៅឡើយទេ។*

***ខ. ការខ្វះចំណេះដឹង និងជំនាញលើការផលិត ការកែច្នៃ និងដំណើរការអាជីវកម្ម៖***

*កសិករវ័យក្មេងសម័យបច្ចុប្បន្ន មានជំនាញនិងចំណេះដឹងខាងវិស័យកសិកម្ម និងការដឹកនាំគ្រប់គ្រងមានកម្រិតតិចតួចបំផុត* (IIED *ឆ្នាំ២០១២: ទំព័រ៣១*) *។ ការអភិវឌ្ឍន៍ជំនាញនិងផ្ទេរបច្ចេកវិទ្យា ត្រូវបានគេចាត់ទុកថាជាគន្លឹះដើម្បី «បង្កើតឱ្យមានយុវកសិករគំរូ ដែលបានធ្វើជីវិតរបស់ខ្លួនប្រសើរឡើងដោយការចាប់យកមុខរបរកសិកម្ម»។ ទោះយ៉ាងណា បញ្ហានេះមិនទាន់ត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីរបស់រដ្ឋាភិបាល និងកម្មវិធីសិក្សាតាមសាលានៅឡើយទេ។ យុវជនចូលចិត្តបច្ចេកវិទ្យាថ្មីៗ ប៉ុន្តែស្ថាប័នជាច្រើនមិនបានយល់ពីសេចក្តីប្រាថ្នារបស់ពួកគេ។ ដូច្នេះ ដោយសារតែកង្វះការលើកទឹកចិត្ត កង្វះការគាំទ្រ និងការលើកកម្ពស់ចំណេះដឹងឱ្យបានគ្រប់គ្រាន់ និងជំនាញពិសេសនៅក្នុង បច្ចេកវិទ្យា និងទំនើបកម្មនៃការធ្វើកសិកម្មផងនោះ បានញាំងឱ្យកសិករវ័យក្មេងមិនអាចមើលឃើញពីអនាគតភ្លឺស្វាងរបស់ពួកគេតាមរយៈវិស័យកសិកម្មឡើយ* (Wobst ២០១០)*។*

***គ. សកលភាវូបនីយកម្ម ភាពមិនប្រាកដប្រជា និងការ ប្រែប្រួល តម្លៃ៖ ក្នុង បណ្តាប្រទេសអាស៊ី មួយចំនួន:***

*ដោយសារអត្រាពន្ធទាប ឬប្រព័ន្ធបើកចំហសំរាប់ផលិតផលកសិកម្ម បានញាំងឱ្យកសិករវ័យក្មេងមិនអាចប្រកួតប្រជែងជាមួយក្រុមហ៊ុនធំៗ បានបង្ខំឱ្យពួកគេចាកចេញពី កសិដ្ឋាន និងវិស័យកសិកម្ម។ អស្ថេរភាពតម្លៃផលិតផលកសិកម្ម ជាកត្តាបង្ខំមួយផ្សេងទៀតឱ្យពួកគេចាកចេញ។ ដោយសារការហូតពន្ធក្នុងអត្រាទាប ឬមិនយកពន្ធសម្រាប់ ផលិតផលកសិកម្ម ហាក់ដូចជាបានបើកដៃឱ្យផលិតផលបរទេស ដែលមានតម្លៃទាបជាង វាយលុកទៅលើផលិតផលក្នុងស្រុកយ៉ាងខ្លាំង។ ជាធម្មតាមនុស្សយើង តែងតែចូលចិត្តទំនិញណាដែលមានតម្លៃថោកជាង គឺមិនចូលចិត្តទំនិញថ្លៃៗនោះទេ។ ដោយសារតែមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី* (FTAs ) *នានាបានបណ្តាលឱ្យកសិករខ្នាតតូចមួយចំនួនបានរងការខាតបង់ ទីបំផុតពួកគេត្រូវបង្ខំចិត្តឱ្យចាកចេញពីការងារកសិកម្ម។*

## ការផ្តួចគំនិតដើម្បីឱ្យមានការទាក់ទាញចំណាប់អារម្មណ៍ យុវជនឱ្យងាកទៅរកមុខរបរកសិកម្មវិញ

១. ***ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ៖*** *នៅក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ដើម្បីជាការឆ្លើយតបទៅនឹងវិបត្តិស្បៀងអាហារនៅទូទាំងពិភពលោកនោះ បណ្តាប្រទេសជាសមាជិករបស់អាហ្វា (AFA) អង្គការសង្គមស៊ីវិល រដ្ឋាភិបាល និងភ្នាក់ងារអង្គការសហប្រជាជាតិ បានចាប់ផ្តើមអភិវឌ្ឍន៍ការកសាងសមត្ថភាព និងភាពជាអ្នកដឹកនាំរបស់កសិករ និងអង្គការកសិករ ដោយផ្តោតជាពិសេសទៅលើយុវជននៅជនបទ។ នៅប្រទេសខ្លះវេទិកាកសិករត្រូវបានបង្កើតឡើងតាមរយៈសិក្ខាសាលា ការកសាងសមត្ថភាព និងកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំជាមួយគ្នា។ កម្មវិធីទស្សនៈកិច្ចសិក្សា ផ្លាស់ប្តូរបទពិសោធន៍និងចំណេះដឹងរបស់កសិករក្នុងការកសាងចំណេះដឹងដល់កសិករក៏ត្រូវបានធ្វើ។*

| ***ប្រអប់១***: *<u>យុវកសិករកសិកម្មសរីរាង្គនៅប្រទេសជប៉ុន</u>*<br>*នៅប្រទេសជប៉ុន កសិករសរីរាង្គវ័យក្មេងថ្មីចំនួនប្រាំមួយអាចរកប្រាក់ចំណេញដុលជាមធ្យមប្រមាណជា ៨.៨៦០.០០០យ៉េន នៅក្នុងឆ្នាំ២០១៣ មានការកើនឡើង២០៧%។ ពួកគេបានថ្លែងអំណរគុណ និងដឹងគុណចំពោះការគាំទ្រពេញទំហឹងទាំងជំនាញ ទាំងដី ទាំងផ្ទះ និងទីផ្សារ ឱ្យពួកគេដោយគ្រូបណ្តុះបណ្តាលកសិករ (កសិករផ្សព្វផ្សាយ) ទើបពួកគេទទួលបានជោគជ័យដូច្នេះ។ កសិករវ័យក្មេងថ្មីៗ ត្រូវការជំនាញខាងកសិកម្មរបស់ខ្លួនតាមរយៈការបណ្តុះបណ្តាលពីកសិករចាស់ៗ ឬដែលមានបទពិសោធន៍ខ្ពស់ មិត្តកសិករនៅក្នុងតំបន់ក្បែរខាង មន្ត្រីផ្សព្វផ្សាយកសិកម្មរបស់រដ្ឋាភិបាល ការចូលរួមវគ្គបណ្តុះបណ្តាល អានសៀវភៅ និងស្រាវជ្រាវតាមអ៊ីនធឺណិត។ ពួកគេបានក្លាយជាមនុស្សឯករាជ្យនៅក្នុងរយៈពេលខ្លី។ បន្ទាប់មកពួកគេបានចាប់ផ្តើមបណ្តុះបណ្តាល បន្តដល់យុវជនចំណូលថ្មីផ្សេងទៀត។ ដូចគ្នានេះផងដែរ ដែលពួកគេបានពង្រឹងកិច្ចសហប្រតិបត្តិការរបស់ពួកគេ និងទទួលបានការគាំទ្រកាន់តែខ្លាំងឡើងតាមរយៈការរៀបចំក្រុមអង្គការកសិកម្មសរីរាង្គ ដ៏សំខាន់ចំនួនបីក្រុម។ ពួកគេទទួលបាន អតិថិជនរបស់ពួកគេតាមរយៈវិធីសាស្ត្រសំខាន់បីៈ អ្នកជានា/បញ្ជាក់ (ដោយកសិករដើមចាស់ និងមិត្តភក្តិ) ការស្វែងរកដោយខ្លួនឯង និងតាមអ៊ីនធឺណិត។* |
|---|



**ប្រអប់ទី២**: កម្មវិធីកសិកម្មថ្មី, ទីក្រុងតៃណាន់, កោះតៃវ៉ាន់

បច្ចុប្បន្នមានកសិករវ័យក្មេងចុះឈ្មោះចូលរៀនក្នុងកម្មវិធីនេះចំនួប២៦៨នាក់ (ក្នុងនោះមានស្ត្រី១៤%) ហើយទាំងអស់គ្នាមានក្រោម៤៥ឆ្នាំ បច្ចុប្បន្នជាកសិករ និងអ្នកដែលប្រាថ្នាក្លាយជាកសិករ។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្មរបស់រដ្ឋាភិបាលបានផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់កសិករវ័យក្មេងទាំងនេះ។ ការគាំទ្របច្ចេកទេស ត្រូវបានផ្តល់តាមរយៈអ្នកជំនាញ យុវជនហាត់ការ វគ្គបណ្តុះបណ្តាលកសិកម្ម និងប្រព័ន្ធប្រឹក្សាយោបល់។ ក្រុមអ្នកជំនាញខាងវិស័យកសិកម្ម និងគ្រូកសិកម្ម ដែលបង្រៀន ដល់កសិករវ័យក្មេង ត្រូវបានដាក់ពង្រាយតាមសមាគមកសិករក្នុងស្រុកនិមួយៗ។ ឯការគាំទ្រផ្នែកហិរញ្ញវត្ថុវិញ គឺបានមកពីការផ្តល់ប្រាក់កម្ចីរបស់រដ្ឋាភិបាលដែលមានអាត្រាការប្រាក់ទាបឱ្យដល់កសិករវ័យក្មេង ដើម្បីទិញឧបករណ៍ផ្គត់ផ្គង់ ឬសម្ភារៈកសិកម្មផ្សេងៗ។ កសិករវ័យក្មេងថ្មីៗមួយចំនួនធំបានទទួលជោគជ័យក្លាយជាកសិករសេដ្ឋីវ័យក្មេង និងឈ្នះការប្រកួតក្នុងការផលិត អង្ករសរីរាង្គ ឈើរីសរីរាង្គ និងប៉េងប៉ោះសរីរាង្គ។

២. **ការពិភាក្សាអំពីកសិកម្មលក្ខណៈគ្រួសារ៖** ការហូរចូលនៃក្រុមហ៊ុនចម្រុះជាតិសាសន៍ ការរំលោភដីធ្លី និងការធ្វើកសិកម្ម របស់ក្រុមហ៊ុនធំៗ នាំឱ្យមានការជជែកពិភាក្សាគ្នា យ៉ាងច្រើនទៅលើការធ្វើកសិកម្មជាលក្ខណៈគ្រួសារ និងសេដ្ឋកិច្ចរបស់អ្នកស្រែចំការ។ អង្គការសហប្រជាជាតិបានប្រារព្ធទិវាឆ្នាំអន្តរជាតិនៃគ្រួសារកសិករនៅឆ្នាំ២០១៤ ហើយមានអង្គការសង្គមស៊ីវិល អង្គការកសិករ និងស្ថាប័នរដ្ឋាភិបាលជាច្រើន បានគាំទ្រ។ អង្គការសង្គមស៊ីវិល អង្គការកសិករ ដែលធ្វើការលើវិស័យកសិកម្ម និងស្បៀងអាហារ បានចាប់ផ្តើមជជែកគ្នានឹងមានឥទ្ធិពលលើគោលនយោបាយ ស្តីពីការធ្វើកសិកម្មជា

លក្ខណៈគ្រួសារ និរន្តរភាពកសិកម្មតាមប្រព័ន្ធអេកូឡូស៊ី និងការបង្កើន អំណាចឥទ្ធិពលរបស់កសិករចូលទីផ្សារ។ ការផ្ដោតលើកសិកម្មជាលក្ខណៈគ្រួសារ បានចូលរួមចំណែកជាពិសេសក្នុងទាក់ទាញចំណាប់អារម្មណ៍យុវជនឱ្យមានការ យកចិត្តទុកដាក់ក្នុងវិស័យកសិកម្ម។



***៣. ការអភិវឌ្ឍន៍កសិកម្មតាមប្រព័ន្ធអេកូឡូស៊ី និង កសិកម្មសរីរាង្គ ប្រកបដោយចេរភាព៖*** របៀបរស់នៅថ្មីរបស់មនុស្សភាគច្រើន(សម័យឥឡូវ) បានចាប់ផ្ដើមងាកមកឱ្យតម្លៃ និងចូលចិត្តអាហារសរីរាង្គព្រោះហេតុផលសុខភាព។ ជាលទ្ធផល ចំនួនកសិករ ដែលធ្វើកសិកម្មសរីរាង្គកើនឡើង។ ទិដ្ឋភាពជាវិជ្ជមានក្នុងសេណារីយ៉ូនេះ បង្ហាញថាមាន យុវជនមួយចំនួនធំបានងាកមកចាប់អារម្មណ៍ ចំពោះការផ្សព្វផ្សាយកសិកម្មសរីរាង្គ និងការចូលរួមរបស់ពួកគេកាន់តែច្រើនឡើង។ សម្រាប់យុវកសិករ ការធ្វើកសិកម្មសរីរាង្គផ្ដល់នូវអត្ថន័យល្អក្នុងការងាររបស់ពួកគេ ផ្ដល់ឱកាសបន្ថែមទៀត ដើម្បីធ្វើការបង្កើតគំនិតថ្មី និងការរៀនពីរបៀបចាស់ និងថ្មីនៃការធ្វើកសិកម្ម។ រដ្ឋាភិបាលមួយចំនួនបានផ្ដល់ការគាំទ្រ ដើម្បីលើកកម្ពស់ការធ្វើកសិកម្ម ប្រកបដោយនិរន្តរភាពតាមប្រពន្ធ័កសិកម្មអេកូឡូស៊ីនិងសរីរាង្គ ដែលបានទាក់ទាញយុវជនកាន់តែច្រើនឱ្យងាកទៅរកវិស័យកសិកម្មវិញ។ នៅក្នុងតំបន់អាស៊ីខាងត្បូង ជនចំណាកស្រុក ដែលត្រឡប់មកពី បណ្ដាប្រទេសនៅមជ្ឈឹមបូព៌ា (ឈូងសមុទ្រពែក) បានចាប់ផ្ដើមការធ្វើកសិកម្ម ហើយមួយចំនួនធំបានលើកកម្ពស់ការធ្វើកសិកម្មសរីរាង្គផងដែរ។

***ប្រអប់ទី៣: អាណាស៊ីបាយ៉ាន***

*អាណាស៊ីបាយ៉ាន អាយុ២៨ឆ្នាំ ជាកូនស្រីរបស់ប្ដីប្រពន្ធកសិករពីកោះ មីនដូរ៉ូ ប្រទេសហ្វីលីពីន។ នាងបានបញ្ចប់ការសិក្សាជំនាញផ្នែកចំអិនអាហារបែបពាណិជ្ជកម្ម ប៉ុន្តែនាង បែរជាស្រឡាញ់ការងារកសិកម្ម និងចង់មានកសិដ្ឋានផ្ទាល់ខ្លួន និងគ្រប់គ្រងអាជីវកម្ម កសិដ្ឋានរបស់ខ្លួន។ នាងបានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលមួយស្ដីពីប្រព័ន្ធកសិដ្ឋានសរីរាង្គពហុប្រយោជន៍ ដែលរៀបចំដោយអង្គការ កសិករថ្នាក់ជាតិរបស់ហ្វីលីពីន ឈ្មោះប៉ាគីសាម៉ា។ បន្ទាប់ពីការបណ្ដុះបណ្ដា លរបស់នាងអំពីប្រព័ន្ធកសិដ្ឋានសរីរាង្គពហុប្រយោជន៍នៅឆ្នាំ២០១៨ មក អាណា បានបញ្ចុះបញ្ចូលក្រុមគ្រួសាររបស់នាង ដើម្បីបំលែងដីកសិដ្ឋានទំហំ ២.៥០០ម៉ែត្រការ៉េ របស់គ្រួយសារនាងទៅជាកសិដ្ឋានសរីរាង្គពហុប្រយោជន៍។ នាងបានចាប់ផ្ដើមសាងសង់ទ្រង់ដីកំប៉ុស្ដ៍ ដីកស្រះត្រីមួយ សួនបន្លែ និង ចិញ្ចឹមមាន់តាមគោលការណ៍ធម្មជាតិ។ នាងបានធ្វើឱ្យការប្រើប្រាស់ដីរបស់គ្រួសារនាង គ្រប់ម៉ែត្រ គ្រប់ធីង នៃកសិដ្ឋានអស់លទ្ធភាព និងមានប្រសិទ្ធិភាពខ្ពស់។ ឥឡូវនេះនាង បានផ្សព្វផ្សាយអំពីធ្វើផែនការធ្វើកសិដ្ឋានពហុប្រយោជន៍ដល់កសិករវ័យក្មេងដទៃទៀតនៅក្បែរខាង និងនៅឯនាយភូមិរបស់ពួកគេ។ នាងជាជ័យលាភីម្នាក់ ដែលបានទទួលរង្វាន់ ជាកសិករគំរូ*

ក្នុងអំឡុងពេល ប្រារព្ធពិធីឆ្នាំអន្តរជាតិនៃគ្រួសារកសិករ (IYFF) នៅក្នុងប្រទេសហ្វីលីពីន។

### ៤. ការកសាងអង្គការកសិករៈ

អង្គការសង្គមស៊ីវិល និងសូម្បីតែទីភ្នាក់ងារអង្គការសហប្រជាជាតិ សុទ្ធតែបាន ជួយសម្រួលដល់ដំណើរការនៃការបង្កើតអង្គការកសិករ និងចងក្រងពង្រឹកពួកគេឱ្យមានអំណាច ដើម្បីឱ្យមានការផ្លាស់ប្តូរគោលនយោបាយ និងការធ្វើកសិកម្ម។ ជាមួយគ្នានោះអង្គការកសិករ បានចាប់ផ្តើមបង្កើតក្រុមយុវជនរបស់ពួកគេ។ ការជជែកដេញដោល និងការពិភាក្សាបានផ្តោតលើសិទ្ធិនិងគំនិតផ្តួចផ្តើមរបស់កសិករ។

**ប្រអប់ទី៤: អង្គការ យុវជនក្នុង ប្រទេសម៉ុងហ្គោលី**

នៅប្រទេសម៉ុងហ្គោលី មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានធ្វើការលើបញ្ហារបស់យុវជន ដូចជាសហព័ន្ធយុវជនម៉ុងហ្គោលី ដែលជាអង្គការក្រៅរដ្ឋាភិបាលធំបំផុតនៅប្រទេសម៉ុងហ្គោលី។ គោលបំណងគឺដើម្បីក្លាយជាសំឡេងតស៊ូមតិមួយ សម្រាប់ការអភិវឌ្ឍន៍ និងការពារសិទ្ធិយុវជនគង្វាលចៀម។ អង្គការនេះបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិមួយ នៅខែកុម្ភៈ ឆ្នាំ២០១៤ ដែលមានយុវជន គង្វាលចៀមម៉ុងហ្គោលីវ័យក្មេងជាច្រើននាក់មកពី២១ខេត្តចូលរួម។ គណៈកម្មាធិមួយ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០១៣ មកម៉្លេះ ដើម្បីការពារផលប្រយោជន៍អ្នកគង្វាលវ័យក្មេង។ គណៈកម្មាការនេះកំពុងធ្វើការស្នង់មតិកម្រិតថ្នាក់ជាតិ អំពីការចិញ្ចឹមសត្វរបស់យុវជនវ័យក្មេង។ ក្លឹបយុវសហករណ៍ថ្នាក់ជាតិមួយត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១០ និងទទួលបានជោគជ័យ ដោយបានរៀបចំកិច្ចប្រជុំលើកដំបូងរបស់ខ្លួនក្នុងឆ្នាំ២០១៣ ស្តីពីភាពជាអ្នកដឹកនាំកសិករវ័យក្មេង។

**ប្រអប់ទី៥: បណ្តាញយុវជននៅប្រទេសកម្ពុជា**

នៅក្នុងប្រទេសកម្ពុជា បណ្តាញកសិករនិងធម្មជាតិ (FNN) បានបង្កើតបណ្តាញយុវជន ដែលតំណាងនៅក្នុងក្រុមប្រឹក្សាភិបាល របស់ខ្លួន។ កសិករវ័យក្មេង ដែលកំពុងត្រូវបានអភិវឌ្ឍន៍ទៅជា អ្នកដឹកនាំសហគមន៍វ័យក្មេង កសិសហគ្រិនតាមរយៈទស្សនៈកិច្ចសិក្សាទៅកាន់កសិដ្ឋានបង្ហាញ និងការអនុវត្តន៍ផ្ទាល់កសិដ្ឋានចិញ្ចឹម រួមទាំងការធ្វើកសិកម្មសរីរាង្គ ការដើកស្រះទឹកចិញ្ចឹមត្រី ការធ្វើកសិកម្មចម្រុះ (កសិដ្ឋានពហុប្រយោជន៍) ការចិញ្ចឹមសត្វ និងការប្រើប្រាស់ ជីលាមកសត្វ និងការផលិតឡជីវឧស្ម័នផងដែរ។

### ៥. ការលើកកម្ពស់កសិករស្ត្រីៈ

ខណៈដែលបុរសៗនៅជនបទធ្វើចំណាកស្រុកទៅទីក្រុង កាន់តែច្រើន និងក្រៅប្រទេសវិស័យកសិកម្មបានក្លាយទៅជាបន្ទុករបស់ស្ត្រី និងមានការជជែកដេញដោលជាច្រើនស្តីពីសិទ្ធិកសិករស្ត្រី និងសិទ្ធិកាន់ដីធ្លីបានចាប់ផ្តើម។ កសិករស្ត្រីបានចូលរួមកាន់តែសកម្មក្នុងការតស៊ូមតិ ដើម្បីសិទ្ធិរបស់ខ្លួន។ នៅក្នុងប្រទេស មួយចំនួនរួមមាន ប្រទេសនេប៉ាល់ ផងដែរ វេទិកា «កសិករស្ត្រី» ត្រូវបានបង្កើតឡើង។

[,



## ៦. ការតស៊ូមតិផ្អែកលើបទពិសោធន៍ជាក់ស្តែង ដើម្បីអោយមានគោលនយោបាយទូលំទូលាយសម្រាប់គ្រួសារកសិករ

អង្គការកសិករនៅក្នុងប្រទេសមួយចំនួនដូចជា ប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន នេប៉ាល់ និងឥណ្ឌា បានរៀបចំការជជែកដេញដោល និងការពិភាក្សាជាសេរី ទៅលើគោលនយោបាយដីធ្លី និងគោលនយោបាយកំណែទម្រង់ទូលំទូលាយមួយស្តីពីកសិកម្ម រួមទាំងសិទ្ធិកាន់កាប់ដីធ្លី ឱកាសទទួលបានកសិកម្មការគាំទ្រសម្ភារៈកសិកម្មល្អ មានតម្លៃទាប ចាត់ចែងដីសម្បទានសង្គមកិច្ច ការបង្កើតនិងការអនុវត្តការប្រើប្រាស់ដី និងគោលនយោបាយសិទ្ធិរបស់កសិករ។ អង្គការកសិករ និងសង្គមស៊ីវិលបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពទាំងនេះ។ កសិករបានប្រមូលផ្តុំខ្លួនឯងនៅក្នុងការតស៊ូមតិដើម្បីការផ្លាស់ប្តូរគោលនយោបាយដីធ្លី និងការកែទម្រង់កសិកម្មនៅក្នុងនាមកសិករវ័យក្មេង។ អង្គការកសិករ សង្គមស៊ីវិល និងភ្នាក់ងារអង្គការសហប្រជាជាតិនៅក្នុងប្រទេសដូចជានេប៉ាល់, ម៉ុងហ្គោលី, កម្ពុជា, ហ្វីលីពីន, ឥណ្ឌូនេស៊ី បង់ក្លាដែស និងប្រទេសវៀតណាម បានធ្វើការស្រាវជ្រាវឯកសារ និងករណីការតស៊ូមតិលើ គោលនយោបាយសម្រាប់កសិករវ័យក្មេង។ ពួកគេបានប្រើប្រាស់លទ្ធផលដែលបានរកឃើញពីការស្រាវជ្រាវ និងករណីផ្សេងៗ ដើម្បីបង្កើនឥទ្ធិពលទៅលើរដ្ឋាភិបាល និងអ្នកបង្កើតគោលនយោបាយរបស់ខ្លួន។ បន្តិចម្តងៗ អង្គការក្រៅរដ្ឋាភិបាល និងអង្គការទេ្វភាគីរវាងប្រទេសនិងប្រទេស បានផ្លាស់ប្តូរជំហរឆ្ពោះទៅគាំទ្រកសិករវ័យក្មេង និងការវិនិយោគនៅក្នុងវិស័យកសិកម្ម។

**ប្រអប់ទី៦: កសិករវ័យក្មេងនៅក្នុងប្រទេសកូរ៉េ**

យោងតាមសហព័ន្ធកសិករឈានមុខកូរ៉េខាងត្បូង (KAFF) និងសហព័ន្ធកសិករស្ត្រីឈានមុខកូរ៉េខាងត្បូង (WAFF) បានឱ្យដឹងថាទោះបីជាមានបញ្ហាច្រើននៅក្នុងវិស័យកសិកម្មក៏ដោយ តែវាជាគឺក្តីសង្ឃឹម។ ជាការឆ្លើយតបទៅនឹងការកើនឡើងនៃបញ្ហារឹបអូសយកដីកសិកម្ម ពីសំណាក់សាជីវកម្មធំៗនោះ រដ្ឋាភិបាលបានចេញប្បញ្ញត្តិលើសិទ្ធិជាម្ចាស់ដីសម្រាប់កសិករណា ដែលធ្វើកសិកម្មលើដីនោះអស់

*រយៈពេលប្រាំឆ្នាំ នោះនឹងក្លាយជាម្ចាស់ដី។ ដើម្បីដោះស្រាយតម្រូវការរបស់កសិកររងផលប៉ះពាល់ដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) រដ្ឋាភិបាលបានបង្កើតគោលនយោបាយមួយដើម្បីធានាថាវិស័យឧស្សាហកម្មដែលទទួលបានពី FTA ត្រូវបង្កើតមូលនិធិគាំទ្រដល់វិស័យកសិកម្ម ក្នុងការជួយឱ្យពួកគេរកប្រាក់ចំណេញដើម្បីវិនិយោគក្នុងវិស័យកសិកម្មបានផង។ ថ្មីៗនេះ កសិករជនជាតិកូរ៉េ ដែលជាអ្នកធ្វើស្រូវ បានទៅចរចារទាមទារសំណងពីរដ្ឋាភិបាល ចំពោះការខាតបង់ទាំងរបស់ពួកគេ ដែលទទួលរងផលប៉ះពាល់ដោយសារតែកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ វាត្រូវបានចាត់ទុកថាជាកាតព្វកិច្ចរបស់រដ្ឋាភិបាលដើម្បីធានាឱ្យបាននូវការរស់នៅរបស់កសិករកូរ៉េ។ សហព័ន្ធកសិករឈានមុខកូរ៉េខាងត្បូង បានស្នើឱ្យមានគោលនយោបាយ៖ (១) ធានាឱ្យបាននូវការជោគជ័យរបស់កសិករនៅក្នុងកសិដ្ឋានលក្ខណៈគ្រួសារដោយការផ្តល់នូវ អំណោយទាយជ្ជទាន បច្ចេកទេស និងការអប់រំដើម្បីលើកកម្ពស់ដល់កសិកម្មប្រព័ន្ធ អេកូឡូស៊ីឱ្យកាន់តែល្អប្រសើរជាងមុន (២) លើកលែងឱ្យកសិករវ័យក្មេងបានរួចផុតពីកាតព្វកិច្ចយោធា (៣) ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់កសិករវ័យក្មេងដោយបញ្ចុះអត្រាការប្រាក់ពី ៣% ក្នុងមួយឆ្នាំនាពេលបច្ចុប្បន្ន ទៅ១% ក្នុងមួយឆ្នាំ (៤) អនុញ្ញាតឱ្យសមាជិកនៃសមាគមយុវកសិករចូលរួមដោយសកម្មក្នុងសកម្មភាពរបស់ សហព័ន្ធកសិករឈានមុខកូរ៉េខាងត្បូង និង (៥) បង្កើនការទទួលខុសត្រូវផ្នែកសង្គមរបស់កសិករវ័យក្មេង និងការអភិវឌ្ឍសមត្ថភាពរបស់ពួកគេជាអ្នកដឹកនាំកសិកម្មក្នុងតំបន់។*

**តើអ្វីរដ្ឋាភិបាលរបស់យើងអាចធ្វើបាន ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់យុវជនឱ្យងាកទៅរកវិស័យកសិកម្ម និងឱ្យពួកគេបន្តស្នាក់នៅជនបទ**

*ផ្អែកលើការសំភាសន៍ និងការសង្កេតរបស់យើងជាមួយយុវជនជនបទ ការផ្ចុះបញ្ចាំងរបស់យើងគឺថាដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់យុវជន ឱ្យងាកទៅរកវិស័យកសិកម្មបានលុះត្រាតែ៖ (១) ប្រាក់ចំណូលពីវិស័យកសិកម្ម អាចចិញ្ចឹមបីបាច់គ្រួសាររបស់ពួកគេបានគ្រប់គ្រាន់ និងសមរម្យថ្លៃថ្នូរ (២) ពួកគេត្រូវបានផ្តល់នូវធនធាន ជាមូលដ្ឋាន ជា ដីធ្លី ទុនគ្រឹះ ដូចវិនិយោគ ការបណ្តុះបណ្តាល ឧបករណ៍ និងសម្ភារៈកសិកម្ម និងមានទីផ្សារត្រឹមត្រូវ (៣) ពួកគេអាចមើលឃើញពីសារៈសំខាន់ និងអត្ថន័យនៅក្នុងការងារវិស័យកសិកម្ម។ បើដូច្នោះមែន អនុសាសន៍ខាងក្រោម ឬសកម្មភាពមួយចំនួននឹងអនុញ្ញាតឱ្យ និងជំរុញឱ្យកសិករវ័យក្មេងបោះបង់គំនិតអវិជ្ជមានរបស់ខ្លួនចំពោះវិស័យកសិកម្មដោយសម្លឹងមើលអំពីសក្តានុពលដើម្បីក្លាយជាមនុស្សខ្លួនទីពឹងខ្លួនក្នុងវិស័យស្បៀងអាហារ និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងរួមបញ្ចូល។ អនុសាសន៍ទាំងនេះ ត្រូវបានញ៉ាំងដោយគំនិតផ្តួចផ្តើមដែលទទួលបានជោគជ័យដូចរៀបរាប់ខាងលើ។*

១. *ផ្តល់ភាពជាម្ចាស់លើសិទ្ធិប្រើប្រាស់ ឬជួលដីធ្វើកសិកម្មយ៉ាងហោចណាស់រយៈពេល២៥ឆ្នាំ ជូនដល់កសិករវ័យក្មេង។ បើគ្មានសន្តិសុខលើសិទ្ធិកាន់កាប់ដីធ្លីរយៈពេលវែងដោយយុវជនទេ អញ្ចឹងយុវជននឹងមិនចាប់អារម្មណ៍ក្នុងការធ្វើកសិកម្មនៅក្នុងភូមិរបស់ពួកគេទេ។*

២. ផ្ដល់កម្មវិធីពិសេស និងកម្មវិធីកសិកម្មចម្រុះ និងការផ្ដល់សេវាការគាំទ្រដល់កសិករវ័យក្មេងរួមទាំងការអប់រំ ការបណ្ដុះបណ្ដាល និងការផ្សព្វផ្សាយកសិកម្ម វគ្គបណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំ កម្ចីឥណទាន បច្ចេកទេស ធាតុចូលកសិកម្ម សម្ភារៈឧបករណ៍កសិកម្មសមស្រប គ្រឿងយន្តកសិកម្ម ការឧបត្ថម្ភធន ធានារ៉ាប់រង និងទីផ្សារ។ កម្មវិធីសាលាគួរតែលើកទឹកចិត្តវិស័យកសិកម្មជាវិជ្ជាជីវៈមួយ ។ កសិករវ័យក្មេងអាចនឹងទទួលបានការបណ្ដុះបណ្ដាលជាសហគ្រិនវ័យក្មេងជនបទ ដោយផ្ដោតលើការកែច្នៃប្រកបដោយនិរន្តរភាព ផ្ដោតលើមូលដ្ឋានផលិតកម្មកសិកម្ម និងការបង្កើតសហករណ៍កសិកម្មពហុបំណង ដែលកត្តាទាំងនេះផ្ដល់នូវអត្ថន័យ និងបណ្ដុះនូវមនោគមប្រាកដនិយម បន្ថែមទៀតថាក្នុងជីវិតរបស់ពួកគេ។ ការផ្ដល់ការទទួលស្គាល់ជាសាធារណៈដល់កសិករឆ្នើមវ័យក្មេងអាចជាឧទាហរណ៍ សម្រាប់អ្នកដែលមានលទ្ធភាពក្នុងការទទួលបានជោគជ័យក្នុងការកសាងសហករណ៍កសិកម្ម។ កសិករស្ត្រីវ័យក្មេង ក៏គួរត្រូវបានផ្ដល់ការយកចិត្តទុកដាក់ផងដែរ ព្រោះស្ត្រីជនភាគច្រើនតែងតែបាត់បង់ឱកាសដោយសារតែរចនាសម្ព័ន្ធវណ្ណៈក្នុងសង្គម ដែលមានស្រាប់ និងការអនុវត្តន៍ដែលនៅតែមានសក្ដានុពល។

៣. ផ្ដល់មធ្យោបាយដល់កសិករវ័យក្មេង ឱ្យពួកគេអាចរៀបចំអ្វីៗដោយខ្លួនឯង ដូចជាការរៀនសូត្រពីគ្នាទៅវិញទៅមក ការចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងដំណើរការបង្កើតគោលនយោបាយ។ កសិករ វ័យក្មេងត្រូវការអារម្មណ៍កក់ក្ដៅមួយអំពីភាពជាម្ចាស់នៃគោលនយោបាយនិងកម្មវិធីដែលទាក់ទងនឹងពួកគេ។ រៀបចំឱ្យមានទស្សនកិច្ចសិក្សាក្នុងចំណោមប្រជាកសិករវ័យក្មេង ទាំងក្នុងនិងក្រៅប្រទេស ដើម្បីបង្កើនចំណេះដឹង និងការផ្លាស់ប្ដូរបទពិសោធន៍។ បង្កើតមជ្ឈមណ្ឌលព័ត៌មានផ្ដោតសម្រាប់យុវជន។

៤. ស្ដារស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ សន្តិភាព និងសណ្ដាប់ធ្នាប់នៅតាមតំបន់ជនបទក៏ព្រមទាំងផ្ដល់នូវសន្តិសុខសង្គម និងការការពារដល់ប្រជាកសិករវ័យក្មេង។

៥. កសិករនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកគឺជាកសិករលក្ខណៈគ្រួសារ ដែលក្រីក្រ និងស្រេកឃ្លាន (អសន្តិសុខស្បៀង) បំផុតនៅលើពិភពលោក។ បច្ចុប្បន្ន ការគាំទ្រកសិករក្ខណៈគ្រួសារតាមរយៈការកែលំអគោលនយោបាយទូលំទូលាយនិងកម្មវិធីរួមបញ្ចូលនានាស្ដីពីការកែទម្រង់វិស័យកសិកម្ម ការអភិវឌ្ឍន៍ជនបទប្រកបដោយចីរភាព ការអនុវត្តប្រព័ន្ធកសិកម្មអេកូឡូស៊ី ទីផ្សារនិងពាណិជ្ជកម្មនឹងបង្កើនប្រាក់ចំណូល និងភាពរឹងមាំរបស់កសិករ ហើយដែលជាបច្ច័យមួយអាចផ្លាស់ប្ដូរទស្សនៈរបស់យុវជន អំពីការធ្វើកសិកម្មបានផងដែរ។

**តើអាហ្វា អាចធ្វើអ្វីបានដើម្បីលើកកម្ពស់វិស័យកសិកម្មក្នុងចំណោមយុវវ័យ** ?

១. ***ការតស៊ូមតិ គោលនយោបាយ:*** កសិករភាគច្រើននៅតំបន់អាស៊ីមានការព្រួយបារម្ភ អំពីបញ្ហាគោលនយោបាយ។ អាហ្វា អាចជួយសម្របសម្រួលដល់បញ្ហារួមក្នុងតំបន់ដូចជាបញ្ហាគោលនយោបាយសេរីនិយមបែបថ្មី បញ្ហាអង្គការពាណិជ្ជកម្មពិភពលោកនៅក្នុងវិស័យកសិកម្ម បញ្ហាការផ្លាស់ប្ដូរអាកាសធាតុ ការធ្វើពាណិជ្ជកម្មសេរី បញ្ហាការរឹបអូសដីធ្លី បញ្ហាសិទ្ធិកសិករវ័យក្មេងនិងស្ត្រី បញ្ហា

សន្តិសុខសង្គម និងបញ្ហាដទៃទៀត។ អាហ្វា អាចធ្វើការបញ្ចុះបញ្ចូលទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការរដ្ឋាភិបាលនានា ដែលមានលក្ខណៈស្និទ្ធិស្នាលមិត្តភាពជាមួយ កសិករ កម្មវិធីនយោបាយ និងការគាំទ្រ។

២. ***ការកសាងសម្ព័ន្ធភាពក្នុងចំណោមអង្គការកសិករ:*** *បញ្ហាដីធ្លី និងបញ្ហាកសិកម្ម គឺជាបញ្ហានយោបាយ ដែលអាចបានដោះស្រាយបានតាមរយៈនយោបាយប៉ុណ្ណោះ។ ដូច្នេះ វាជាការសំខាន់ក្នុងការសម្របសម្រួលឱ្យមានការចូលរួមពីតំណាងរដ្ឋាភិបាលពាក់ព័ន្ធ តាមរយៈការផ្តល់ឱកាសប្រមូលផ្តុំរបស់សហគមន៍នៅថ្នាក់ជាតិ និងអន្តរជាតិ។ ក្នុងន័យនេះ អាហ្វា អាចជួយសម្រួលដល់ដំណើរការកសាងសម្ព័ន្ធភាពក្នុងចំណោមអង្គការ និងអង្គការសង្គមស៊ីវិល ឆ្ពោះទៅរកការប្រមូលផ្តុំបែបនេះបាន។*

៣. ***កម្មវិធីផ្លាស់ប្តូរកសិករវ័យក្មេង:*** *សមាជិករបស់អាហ្វា និងអង្គការកសិករផ្សេងទៀត បានបង្កើតម៉ូដែលគំរូស្តីពីកសិកម្មប្រកបដោយចីរភាព។ អាហ្វា អាចជួយសម្របសម្រួលដល់ដំណើរការកម្មវិធីផ្លាស់ប្តូរកសិករវ័យក្មេងនេះបាន ដើម្បីកសាងចំនេះដឹងរបស់កសិករវ័យក្មេងស្តីពីការធ្វើកសិកម្មបច្ចេកទេសកសិកម្មថ្មី បង្កើតគោលនយោបាយថ្មី និងទាក់ទាញយុវជនក្នុងឱកាសទៅរកវិស័យកសិកម្មវិញ។*

៤. ***ភាពជាដៃគូក្នុងចំណោមអង្គការកសិករ:*** *និរន្តរភាពកសិកម្មលក្ខណៈគ្រួសារនិងយុវជនក្នុងវិស័យកសិកម្ម មិនអាចទៅរួចទេបើគ្មានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសទេនោះ។ ដូច្នេះ អាហ្វា អាចជួយសម្រួលដល់ដំណើរការនៃភាពជាដៃគូ ក្នុងចំណោមអង្គការកសិករ និងអង្គការសង្គមស៊ីវិល ដែលធ្វើការនៅក្នុងវិស័យកសិកម្មប្រកបដោយនិរន្តរភាព ដើម្បីទាក់ទាញការគាំទ្រ និងការលើកកម្ពស់វិស័យកសិកម្មពីម្ចាស់ជំនួយ នៅក្នុងតំបន់ និងប្រទេសនិមួយៗ។*



៥. ***ស្រាវជ្រាវនិង ការបោះពុម្ភ:*** *ការស្រាវជ្រាវ និងការបោះពុម្ភស្តីពីធ្វើការកសិកម្មរបស់គ្រួសារកសិករ ឬយុវជនគឺជាផ្នែកមួយដ៏សំខាន់។ បញ្ហាមួយចំនួនទាមទារ ឬតម្រូវឱ្យមានការសិក្សា និងការពិភាក្សាជាមួយរដ្ឋាភិបាលជាមួយទីភ្នាក់ងារម្ចាស់ជំនួយនានា។ អាហ្វា អាចធ្វើការស្រាវជ្រាវ និងការសន្ទនាដោយផ្ទាល់បាននៅកម្រិតតំបន់និងផ្តល់ការគាំទ្រដល់សមាជិកនៅកម្រិតប្រទេសនីមួយៗបាន។*

## សន្និដ្ឋាន

*ប្រមាណជាហុកសិបភាគរយ (៦០%) ស្មើនឹង ៧៥០.០០០.០០០នាក់នៃចំនួនយុវជនរបស់ពិភពលោក គឺកំពុងរស់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ប្រមាណ៧០% ប្រហែលចំនួន៥២៥.០០០.០០០នាក់ក្នុងចំណោមពួកគេកំពុងរស់នៅក្នុងតំបន់ជនបទក្នុងទ្វីបអាស៊ី ហើយជាងពាក់កណ្ដាលនៃពួកគេ បានចូលប្រឡូកដោយផ្ទាល់ក្នុងវិស័យកសិកម្ម។ ទោះយ៉ាងណា យុវជនជនបទភាគច្រើនចូលចិត្តធ្វើចំណាកស្រុកទៅកាន់ទីក្រុង ឬធ្វើការនៅក្រៅប្រទេស។ ចំពោះយុវជនភាគច្រើន ដែលបន្តនៅធ្វើកសិកម្មនោះ គឺដោយសារមិនមានជម្រើសអ្វីប្រសើរជាងនេះ។ ពួកគេបានមើលឃើញការធ្វើកសិកម្ម ជាការងារមួយ ដែលមិនអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ឡើយ វាគឺជាការងារដែល ប្រឈមនឹងហានិភ័យខ្ពស់ ការងារតូចទាប ហើយការគាំទ្រដោយរដ្ឋាភិបាល និងស្ថាប័នដទៃទៀតតិចតួចបំផុត។*

*យ៉ាងណាក៏ដោយ យុវជនអាចត្រូវបានទាក់ទាញឱ្យងាកទៅរកវិស័យកសិកម្មវិញប្រសិនបើ៖ (១) ប្រាក់ចំណូលពីវិស័យកសិកម្មគ្រប់គ្រាន់សម្រាប់ពួកគេដើម្បីបង្កើតគ្រួសារមួយ (២) ទទួលបានការផ្ដល់ធនធានមូលដ្ឋានគ្រឹះ ដូចជា ដីធ្លី កម្ចី ការបណ្ដុះបណ្ដាល សម្ភារៈ និងឧបករណ៍កសិកម្ម ទីផ្សារ និង (៣) ពួកគេអាចមើលឃើញសារៈសំខាន់និងខ្លឹមសារនៅក្នុងការងាររបស់ខ្លួន។*

*ដើម្បីទាញយកសក្ដានុពល និងថាមពលរបស់យុវជននៅក្នុងវិស័យកសិកម្ម នោះត្រូវទាមទារនូវគោលនយោបាយទូលំទូលាយមួយ និងធ្វើសមាហរណកម្ម នូវកម្មវិធីទាំងអស់ ព្រមទាំងធ្វើកំណែទម្រង់កសិកម្ម កម្មវិធីអភិវឌ្ឍន៍ជនបទប្រកបដោយនិរន្តភាព កសិកកម្មតាមប្រព័ន្ធអេកូឡូស៊ី និងការគ្រប់គ្រងសហគ្រាសកសិកម្ម ហើយមូលដ្ឋានទីផ្សារ កសិពាណិជ្ជកម្ម ត្រូវបង្កើត ជាមួយនឹងការលើកទឹកចិត្តជាពិសេស និងផ្ដល់ឱ្យកសិករវ័យក្មេង និងកសិករស្ត្រីផងដែរ។*

*យុវជន គឺជាអនាគតនៃប្រទេសជាតិ ហើយយុវជននៅតាមជនបទ គឺជាអនាគតនៃវិស័យកសិកម្ម និងកសិឧស្សាហកម្មជនបទ។ ពេលវេលាត្រូវចាប់ផ្ដើម គឺពេលនេះហើយ ប្រសិនបើយើងចង់ឱ្យមានកសិករមានស្បៀងអាហារសម្រាប់ពេលអនាគត។*

## សេចក្ដីយោង

*ព្រឹត្តបត្រព័ត៌មានរបស់អាហ្វា* AFA (*ឆ្នាំ២០១៤ ភាគទី១*)

*ការទាក់ទាញយុវជនក្នុងតំបន់អាស៊ី ឱ្យចាប់អារម្មណ៍ងាកទៅរកវិស័យកសិកម្ម: បរិបទនិងទស្សនវិស័យ។ ឯកសារថ្នាក់តំបន់មួយ រាយការណ៍រៀបដោយសមាគមកសិករអាស៊ីសម្រាប់ការអភិវឌ្ឍន៍ជនបទប្រកបដោយនិរន្តភាព* (AFA) *កាលពីខែធ្នូ ឆ្នាំ២០១៤។*

*ព្រឹត្តបត្រព័ត៌មានរបស់អាហ្វា* AFA (*ឆ្នាំ២០១៤៖ ភាគទី២*)

AFA (2014 *ខ*) ។ *ដំណើរការរបស់អាហ្វា ក្នុងមហាសន្និបាតលើកទី៦ និងការពិគ្រោះយោបល់ថ្នាក់តំបន់: «ចុះបញ្ជាំងពីបទពិសោធន៍ជាស៊ីជម្រៅសម្រាប់គ្រួសារកសិករ* IYFF» *នៅថ្ងៃទី៦-៧ ខែឧសភា ឆ្នាំ២០១៤ នៅសណ្ឋាគារសាន់ទីកា នៅកោះបាលីប្រទេសឥណ្ឌូនេស៊ី។*

ព្រឹត្តបត្រព័ត៌មានរបស់អាហ្វា (ឆ្នាំ២០១៤៖ ភាគទី៣)

*សិក្ខាសាលាយុវជនអាហ្វាថ្នាក់តំបន់: ការអភិវឌ្ឍន៍សមត្ថភាព និងពង្រាងរបៀបវារៈសម្រាប់កសិករវ័យក្មេងទ្វីបអាស៊ី (កាលពីថ្ងៃទី២៥-២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅទីក្រុងកេហ្សូន ប្រទេសហ្វីលីពីន)។*

***លោក Ahmad QaziKholiquzzaman (2010)***

*រៀនពីកំណែទម្រង់រចនាសម្ព័ន្ធដីកសិកម្ម និងទស្សនវិស័យនៃកិច្ចសហប្រតិបត្តិការ ក្នុងវិស័យកសិកម្មនៅតំបន់អាស៊ីខាងត្បូង។ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចនៅ តំបន់អាស៊ីខាងត្បូង បញ្ហា និងមាគ៌ាឆ្ពោះទៅមុខ។*

*ទីក្រុងដេលី: ក្តីស្រមៃថ្មីសម្រាប់អាស៊ីខាងត្បូង។*




Araghi, F. A.(1995). *Global Depesantization 1945-1990*. USA: The sociological Quarterly, Vol. 36, No. 2 (Spring 1995). Retrieved from http://www.polsci.chula.ac.th/jakkrit/anthro/Rural_Sociology_files/Global%20Depeasantization,.pdf pp.337-368. Accessed on 20 October 2012.

Borras, S.M. (2006). *The underlying assumptions: Theory and practice of neo-liberal policie.,* Retrieved from http://www.foodfirst.org/files/bookstore/pdf/promisedland/5.pdf and accessed on 7th January 2014.

Harvey, D. (2003). *The New Imperialism.* London: Oxford University, University Press.

Hu, J., Yeh, A., Wu, F.(2009). *Land commodification: New land development and politics in China since late 1990s.* International Journal of Urban and Regional Research, Volume 33. 4 December 2009, 890-913. Retrieved from from http://www.grm.cuhk.edu.hk/eng/research/RAE2011/XuJiang/2_IJURR_2009.pdfand accessed on 14 January 2014.

IFAD (2011). *Feeding future generations: Young rural people today – prosperous, productive farmers tomorrow.* Proceedings of the Governing Council High-Level Panel and Side Events.
IIED (2012). *Small-scale farming and youth in an era of rapid rural change.* Retrieved from http://pubs.iied.org/pdfs/14617IIED.pdf and accessed on 7th of April 2015.
Kumar, A. (2011). *Land in the neo-liberal times: A commodity or social good.* Institute of Town Planning, India Journal 8-208, April -June 2011, Retrieved from http://itpi.org.in/files/apr2_11.pdf and accessed on 17th January 2014.
Peters, David J. (2002). *Revisiting the Goldschmidt Hypothesis: The Effect of Economic Structure on Socioeconomic Conditions in the Rural Midwest*. Missouri Department of Economic Development, Technical Paper. P-0702-1, (Jefferson City: Missouri Department of Economic Development, 2002).
Shrestha, N. (2001). *The Political Economy of Land, Landlessness and Migration in Nepal.* Nepal: Nirala Publications.
United Nations Foundation (2011). *Largest youth generation in history at crossroads*. 25 February 2011. Retrieved from http://www.unfoundation.org/news-and-media/press-releases/2011/largest-youth-generation-in-history-at-crossroads.html?referrer=https:/ and accessed on 17 January 2015.
Wobst, P. (2010). *Promoting Employment and Entrepreneurship for Rural Youth: The Case of the Farmer Field and Life Schools (JFFLS).* 19th CTA Brussels Rural Development Briefing - 16 June 2010.

**CREDITS**

WITER: Jagat Basnet
PEER REVIEW BY: Mary Racelis
EDITORS: Maria Josefa Petilla, Ma. Estrella Penunia, Marciano Virola, Jr.
LAYOUT: Bebs Pavia, Art Angel Printshop
PHOTOS: AFA Photobank
Published by AFA
With support from agriterra
Volume 7, Number 1, June 2015